ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ...៣៩...សលរ...

# សារលិខិត
## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី
## នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈកម្មាធិការសម្របសម្រួលកិច្ចការជនពិការ ក្នុងឱកាសទិវាជនមានពិការភាពកម្ពុជាលើកទី២៦និងអន្តរជាតិលើកទី៤២
## ក្រោមប្រធានបទ
## «បរិយាបន្នពិការភាពលើគ្រប់វិស័យក្នុងយុគសម័យបរិវត្តកម្មឌីជីថល»
## និងពិធីប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០២៤-២០២៨
## ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤

- សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
- សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
- សូមក្រាបថ្វាយបង្គំព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
- សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា
- បងប្អូន ក្មួយៗមានពិការភាព និងជនរួមជាតិ ជាទីស្នេហា

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំមានក្តីសោមនស្សរីករាយក្រៃលែង ដើម្បីផ្ញើសារចូលរួមអបអរសាទរជូនបងប្អូនក្មួយៗមានពិការភាព និងជនរួមជាតិ ជាទីស្រឡាញ់ ក្នុងឱកាសដ៏នក្ខត្តឫក្សនៃការប្រារព្ធទិវាជនមានពិការភាពកម្ពុជាលើកទី២៦និងអន្តរជាតិលើកទី៤២ ក្រោមប្រធានបទ «**បរិយាបន្នពិការភាពលើគ្រប់វិស័យក្នុងយុគសម័យបរិវត្តកម្មឌីជីថល**» នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ និងពិធីប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០២៤-២០២៨។

ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជាមានមោទនភាព ដោយបានចូលរួមរៀបចំប្រារព្ធទិវាដ៏ឱឡារិកនេះ ជាមួយប្រជាជាតិទូទាំងពិភពលោក ជាការអបអរសាទរចំពោះជោគជ័យថ្មីៗនៃវិស័យពិការភាពដែលបង្ហាញអំពីឆន្ទៈដ៏មោះមុតនិងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលនៃប្រទេសនីមួយៗ ក្នុងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងជនមានពិការភាព។

គិតត្រឹមខែតុលា ឆ្នាំ២០២៤នេះ មានក្រសួង ស្ថាប័នចំនួន៣៩ បានទទួលយកជនមានពិការភាពចូលបម្រើការងារចំនួន៣ ៨១៦នាក់ ក្នុងនោះស្ត្រីមានពិការភាពចំនួន៨៨២នាក់ ជនមានពិការភាពកម្រិតធ្ងន់ចំនួន២ ៣៥១នាក់ បើគិតជាភាគរយគឺស្មើនឹង ២,០៤%។ ដោយឡែក វិស័យឯកជនរួមមាន ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សណ្ឋាគារ និងរោងចក្រ បានចុះបញ្ជិកានិងទទួលបានវិញ្ញាបនបត្រលើការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការទូទាំងប្រទេសមានចំនួន២៨៧ បានទទួលយកជនមានពិការភាពចូលបម្រើការងារចំនួន៥ ៦៨៤នាក់ ស្ត្រីមានពិការភាពចំនួន៣ ៥៧៨នាក់។ សរុបទាំងក្រសួង ស្ថាប័នរដ្ឋនិងវិស័យឯកជនទូទាំងប្រទេស បានទទួលយកជនមានពិការភាពចំនួន៩ ៥០០នាក់ ឱ្យបម្រើការងារដោយទទួលបានប្រាក់ចំណូលនិងអត្ថប្រយោជន៍សង្គម ទៅតាមមុខតំណែង តួនាទី និងការងារស្របតាមសមត្ថភាពនិងទេពកោសល្យរៀងៗខ្លួន។

ការងារស្តារលទ្ធភាពពលកម្មកាយសម្បទា បានផ្តល់សេវាជូនជនមានពិការភាពចំនួន២៧ ៧៧៤នាក់ ស្ត្រីចំនួន៦ ៨០៥នាក់ បានផ្តល់សេវាស្តាររវេជ្ជសាស្ត្រចំនួន៣៦ ០៧៤នាក់ ស្ត្រីចំនួន១៨ ០១៥នាក់ បានផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយចំនួន៨ ១៧៤គ្រឿង រួមទាំងបានផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ជូនជនមានពិការភាពបានចំនួន៨ ៥០៥នាក់។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាននិងកំពុងដំណើរការអនុវត្តកម្មវិធីកំណត់អត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គមនិងសិទ្ធិជាមូលដ្ឋាន ដែលបច្ចុប្បន្នជនមានពិការភាពចំនួន៣៥១ ២៧៦នាក់ ក្នុងនោះស្ត្រីចំនួន១៦៦ ០៣៤នាក់ ត្រូវបានកំណត់អត្តសញ្ញាណកម្មតាមរយៈជនបង្គោលឃុំ/សង្កាត់ទូទាំងប្រទេស ហើយបានផ្តល់បណ្ណសម្គាល់ជនមានពិការភាពបានចំនួន២៥០ ៧៣០បណ្ណ។

នៅឆ្នាំ២០២៤នេះ ប្រធានបទគន្លឹះនៃទិវាជនមានពិការភាពកម្ពុជាលើកទី២៦និងអន្តរជាតិលើកទី៤២គឺ **«បរិយាបន្នពិការភាពលើគ្រប់វិស័យក្នុងយុគសម័យបរិវត្តកម្មឌីជីថល»** ក្នុងគោលដៅជំរុញឱ្យមានការដាក់បញ្ចូលវិស័យពិការភាពក្នុងប្រព័ន្ធឧស្សាហកម្មទំនើបជំនាន់ទី៤ ដោយផ្លាស់ប្តូរវិស័យសេដ្ឋកិច្ច សង្គមកិច្ចនយោបាយក្នុងប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនប្រសិទ្ធភាព សុក្រឹតភាព គុណភាព និងគណនេយ្យភាពនៃសេវាកម្មឱ្យកាន់តែប្រសើរជាងមុន។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដែលមានសសរស្តម្ភចំនួន៣ គឺ ពលរដ្ឋឌីជីថល រដ្ឋាភិបាលឌីជីថល និងធុរកិច្ចឌីជីថល។ ពលរដ្ឋឌីជីថល សំដៅដល់ពលរដ្ឋដែលចេះប្រើបច្ចេកវិទ្យាឌីជីថលក្នុងការងារនិងសកម្មភាពរស់នៅប្រចាំថ្ងៃ, រដ្ឋាភិបាលឌីជីថល សំដៅដល់ទំនើបកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនិងសេវាសាធារណៈតាមប្រព័ន្ធឌីជីថល, និងធុរកិច្ចឌីជីថល សំដៅដល់ការគ្រប់គ្រងសេវាកម្មឯកជន អាជីវកម្ម មុខជំនួញចម្បងៗដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ទន្ទឹមនឹងបរិវត្តកម្មបច្ចេកវិទ្យាដ៏មានសក្តានុពលជានិន្នាការសកលដែលពិភពលោកកំពុងតែអបអរសាទរនិងទទួលយកមកប្រើជាប្រយោជន៍ល្អៗនានា ក៏នៅមានបញ្ហាប្រឈមជាសកលខ្លះៗដែលបណ្តាលមកពីការប្រើប្រាស់បច្ចេកវិទ្យាខុសទិសដៅ ហើយបាននិងកំពុងកាត់បន្ថយល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងសហប្រតិបត្តិការអន្តរជាតិផងដែរ ដូចជា សង្គ្រាមនៅអ៊ុយក្រែននិងមជ្ឈិមបូព៌ា ដែលនៅតែបន្តហើយបាននិងកំពុងបង្កើតហានិភ័យថ្មីៗលើការអភិវឌ្ឍនានា ក្នុងនោះក៏បានប៉ះពាល់ដល់វិស័យពិការភាពនិងសិទ្ធិមនុស្សជាសកលផងដែរ។

ស្របពេលជាមួយនឹងការអបអរសាទរទិវាជនមានពិការភាពកម្ពុជាលើកទី២៦និងអន្តរជាតិលើកទី៤២ ឆ្នាំ២០២៤នេះ តាងនាមរាជរដ្ឋាភិបាលកម្ពុជានិងជាប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ ខ្ញុំសូមប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ **«ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០២៤-២០២៨»** និងសូមអំពាវនាវដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ត្រូវរួមគ្នាបន្តខិតខំអនុវត្តឱ្យកាន់តែទទួលបានជោគជ័យដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅធានាឱ្យបានកំណើនសេដ្ឋកិច្ច បង្កើតការងារឱ្យបានកាន់តែច្រើន សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ បន្តពង្រឹងសមត្ថភាពអភិបាលកិច្ច និងលើកកម្ពស់គុណភាពស្ថាប័ន ធានាឱ្យបាននូវចីរភាពនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ដោយផ្តល់អាទិភាពគន្លឹះលើមនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ដែលជាគោលដៅធំបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៧នៃរដ្ឋសភា ដូចដែលបានកំណត់យ៉ាងច្បាស់លាស់រួចហើយនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។

ដើម្បីចូលរួមអបអរសាទរ **ទិវាជនមានពិការភាពកម្ពុជាលើកទី២៦និងអន្តរជាតិលើកទី៤២ និងពិធីប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០២៤-២០២៨** ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមធ្វើការអំពាវនាវដូចតទៅ៖

១- គ្រប់ក្រសួង ស្ថាប័នទាំងអស់ត្រូវខិតខំកសាងសមត្ថភាពមន្ត្រីរាជការរួមទាំងមន្ត្រីមានពិការភាពឱ្យចេះប្រើប្រាស់ឌីជីថលនៅក្នុងសម័យកាលថ្មីនេះ ដើម្បីជាប្រយោជន៍ដល់ការងាររបស់អង្គភាពនិងសកម្មភាពរស់នៅប្រចាំថ្ងៃ។

២- គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ អង្គការដៃគូនានា វិស័យឯកជន និងតួអង្គពាក់ព័ន្ធទាំងអស់ ត្រូវខិតខំអនុវត្តឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផលនូវ **«ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០២៤-២០២៨»** ដោយដាក់បញ្ចូលគោលដៅដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រនេះ ទៅក្នុងផែនការសកម្មភាពឬកម្មវិធីប្រចាំឆ្នាំរបស់ខ្លួន និងកំណត់នូវសូចនាករសមិទ្ធផលសម្រាប់អនុវត្តរយៈពេលខ្លី មធ្យម និងវែង ហើយត្រូវធ្វើរបាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សាសកម្មភាពជនពិការបូកសរុបជារបាយការណ៍ជាតិ។

៣- ក្រសួង ស្ថាប័នដែលបានបង្កើតក្រុមការងារសកម្មភាពជនពិការរួចហើយ ត្រូវបង្កើននិងពង្រឹងប្រសិទ្ធភាពការងារដោយរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងត្រូវកែសម្រួលសមាសភាពជាប្រចាំតាមស្ថានភាពប្រែប្រួលជាក់ស្តែងនៃក្រសួង ស្ថាប័ននីមួយៗ។ ដោយឡែក ក្រសួង ស្ថាប័ន ដែលមិនទាន់បានបង្កើតក្រុមការងារសកម្មភាពជនពិការ ត្រូវបង្កើតនិងរៀបចំសមាសភាពឱ្យសមស្របទៅតាមបរិបទការងាររបស់ក្រសួង ស្ថាប័ននីមួយៗ។

៤- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវចូលរួមចំណែកយ៉ាងសកម្មជំរុញការផ្តល់សេវានានាដល់ជនមានពិការភាពឱ្យកាន់តែមានប្រសិទ្ធភាព ដោយប្រើយន្តការអន្តរវិស័យដែលមានស្រាប់ គឺក្រុមប្រឹក្សាសកម្មភាពជនពិការនៅតាមរាជធានី ខេត្តនីមួយៗ និងធ្វើរបាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សាសកម្មភាពជនពិការនៅថ្នាក់ជាតិ ដើម្បីបូកសរុបជារបាយការណ៍ជាតិស្តីពីពិការភាពនៅកម្ពុជា។

៥- គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរគ្រប់ផ្នែក អង្គការដៃគូពាក់ព័ន្ធ និងវិស័យឯកជន ដែលមានការទទួលខុសត្រូវលើសំណង់អគារ និងទីធ្លាសាធារណៈនានា ត្រូវចាប់ផ្តើមកែសម្រួលឬរៀបចំផាសុកវត្ថុសម្រាប់ជនមានពិការភាពនៅតាមសំណង់អគារនិងទីធ្លាសាធារណៈទាំងនោះ ដើម្បីឱ្យជនមានពិការភាពគ្រប់ប្រភេទអាចចេញចូល ចុះឡើង និងប្រើប្រាស់បាន ស្របតាមច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ដោយឈរលើបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។

៦- ក្រសួងសុខាភិបាល និងក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវបន្តសហការគ្នាឱ្យបានល្អជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីផ្តល់បណ្ណបើកបរដល់ជនមានពិការភាពដោយគ្មានឧបសគ្គឬការរើសអើងអ្វីឡើយ ឱ្យស្របតាមប្រកាសអន្តរក្រសួង ស្តីពីលក្ខខណ្ឌនៃការចេញបណ្ណបើកបរសម្រាប់ជនមានពិការភាព។ ក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធនានា រួមទាំងវិស័យឯកជនដែលទទួលខុសត្រូវលើមធ្យោបាយដឹកជញ្ជូនសាធារណៈទាំងតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ត្រូវរៀបចំឬកែសម្រួលមធ្យោបាយដឹកជញ្ជូនសាធារណៈទាំងអស់នោះ ដើម្បីឱ្យជនមានពិការភាពអាចប្រើប្រាស់បាន។

៧- ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវសហការគ្នាឱ្យបានល្អបំផុតក្នុងការផ្តល់សេវាស្តារលទ្ធភាពពលកម្មតាមគំរូវេជ្ជសាស្ត្រ និងស្តារលទ្ធភាពពលកម្មតាមគំរូសង្គមប្រកបដោយគុណភាពនិងដោយមិនគិតថ្លៃ ជូនជនមានពិការភាពដែលក្រីក្រដូចបានកំណត់នៅក្នុងគោល-នយោបាយរបស់រាជរដ្ឋាភិបាល។

៨- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើនប្រសិទ្ធភាពផ្តល់បណ្ណពិការភាព ជូនជនមានពិការភាពគ្រប់រូប ដើម្បីពួកគាត់អាចប្រើប្រាស់បណ្ណស្របតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម និងការទទួលបានផលប្រយោជន៍នានាពីសង្គម។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយព្រះពរ ប្រគេនពរ និងជូនពរ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី បងប្អូន ក្មួយៗមានពិការភាព និងជនរួមជាតិទាំងអស់ សូមប្រកបបាននូវពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃសុក្រ ១៤រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**